# 感染拡大防止のための留意点
# ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការទប់ស្កាត់ការចម្លងវីរុស

新型コロナウイルスの感染拡大を防ぐため、イベントや会食の際には以下の点に留意してください。

ដើម្បីទប់ស្កាត់ការរីករាលដាលវីរុសជំងឺកូរូណាថ្មី សូមមានការប្រុងប្រយ័ត្ននៅពេលមានកម្មវិធី ឬការជួបជុំបរិភោគអាហារ។

- 体調が悪い場合は、イベントや会食に参加しないこと。

  ប្រសិនបើអ្នកមិនស្រួលខ្លួន សូមកុំចូលរួមកម្មវិធី ឬការជួបជុំបរិភោគអាហារ។

- イベントや会食の参加に当たっては、適切な対人距離の確保、手洗・手指消毒、マスクの着用、換気の徹底、大声での会話の自粛など、基本的な感染対策を徹底すること。 なお、屋外において、他者と距離がとれない場合であっても会話をほとんど行わない場合は、マスクの着用は必要ないことに留意すること。

  នៅពេលចូលរួមកម្មវិធី ឬជួបជុំបរិភោគអាហារ សូមអនុវត្តវិធានការមូលដ្ឋានទប់ស្កាត់ការឆ្លងឲ្យបានសព្វគ្រប់ ដូចជាការធានាគម្លាតសុវត្ថិភាពបុគ្គលសមស្រប លាងដៃ/សម្លាប់មេរោគម្រាមដៃ ពាក់ម៉ាស់ ធ្វើការប្តូរខ្យល់ចេញចូលឲ្យបានសព្វគ្រប់ និងចៀសវាងការនិយាយខ្លាំងៗជាដើម។ គួរបញ្ជាក់ថា នៅខាងក្រៅ ត្រូវប្រុងប្រយ័ត្នថាទោះបីក្នុងករណីមិនអាចរក្សាគម្លាតជាមួយអ្នកដទៃបានក៏ដោយ ប្រសិនបើស្ទើរតែមិននិយាយគ្នា នោះមិនចាំបាច់ពាក់ម៉ាសទេ។

- 高齢者や基礎疾患を有する者及びこれらの者と日常的に接する者は、密閉・密集・密接が発生しやすい場所や基本的な感染防止策が徹底されていないイベントや会食への参加を控えること。

  ចំពោះមនុស្សចាស់និងអ្នកដែលមានជំងឺមូលដ្ឋានព្រមទាំងអ្នកដែលប៉ះពាល់ជាមួយបុគ្គល ំងនេះជាប្រចាំថ្ងៃ ត្រូវចៀសវាងការចូលរួមកម្មវិធី ឬការជួបជុំបរិភោគអាហារ ដែលមិនបានចាត់វិធានការមូលដ្ឋានទប់ស្កាត់ការឆ្លងឲ្យបានសព្វគ្រប់ ឬទីកន្លែងបិទជិត មានមនុស្សកកកុញ និងប៉ះពាល់គ្នាជិត ដែលជាកន្លែងងាយឆ្លងវីរុស។

- 必要に応じて、オンラインでイベントに参加することなども検討すること。

  បើចាំបាច់ សូមពិចារណាធ្វើការចូលរួមកម្មវិធីតាមអនឡាញជាដើមផងដែរ។

- 新型コロナウイルス感染症に感染したと疑われる場合で、医療機関への受診等に関して疑問等がある場合には、居住する自治体の相談窓口等に電話すること。
  ប្រសិនបើអ្នកសង្ស័យថា អ្នកបានឆ្លងវីរុសកូរូណាថ្មី រួចមានសំណួរទាក់ទងនឹងការពិនិត្យសុខភាពនៅស្ថាប័នសុខាភិបាល សូមទូរស័ព្ទមកការិយាល័យពិគ្រោះយោបល់របស់រដ្ឋាភិបាល នៅតំបន់ដែលអ្នករស់នៅ។